MN DEPARTMENT OF HEALTH

# ព័ត៌មានអំពីជំងឺរលាកថ្លើមប្រភេទ B សម្រាប់ស្ត្រីមានផ្ទៃពោះ

## តើជំងឺរលាកថ្លើមប្រភេទ B ជាអ្វី?

- ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺថ្លើមដែលបណ្ដាលមកពីវីរុស។ ចំពោះមនុស្សជាច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B វីរុសនេះនៅតែស្ថិតក្នុងរាងកាយដែលបណ្ដាលឱ្យមានជំងឺអស់មួយជីវិត។
- ជំងឺរលាកថ្លើមប្រភេទ B អាចបណ្ដាលឱ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរក្នុងរយៈពេលយូររួមទាំងការខូចថ្លើម ការខ្សោយថ្លើម និងមហារីកថ្លើម។
- មនុស្សភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B មិនមានចេញរោគសញ្ញាទេ ហើយប្រហែលជាមិនដឹងថាខ្លួនគេមានផ្ទុករោគសញ្ញានេះដែរ។ ប៉ុន្តែពួកគេនៅតែអាចចម្លងជំងឺរលាកថ្លើមប្រភេទ B ទៅកាន់អ្នកដទៃ។

## ហេតុអ្វីបានជាស្ត្រីមានផ្ទៃពោះត្រូវធ្វើតេស្ត?

- បើស្ត្រីមានផ្ទៃពោះធ្វើតេស្តទទួលបានលទ្ធផលវិជ្ជមានមានផ្ទុកជំងឺរលាកថ្លើមប្រភេទ B ទារករបស់ស្ត្រីនោះត្រូវតែព្យាបាលនៅពេលកើត។ ទារកដែលទទួលការព្យាបាលនៅពេលដែលពួកគេកើតមកកម្រកើតជំងឺរលាកថ្លើមប្រភេទ B ណាស់។
- នៅពេលទារកឆ្លងមេរោគរលាកថ្លើមប្រភេទ B ពួកគេទំនងជាកើតជំងឺឆ្លងនេះពេញមួយជីវិត។
- មានផ្ទៃពោះគួរតែធ្វើតេស្តរកជំងឺរលាកថ្លើមប្រភេទ B អំឡុងពេលមានផ្ទៃពោះរាល់លើក។

## តើអ្នកគួរធ្វើដូចម្ដេច ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B និងមានផ្ទៃពោះ?

- សូមទៅជួបអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក ដើម្បីពិភាក្សាអំពីរបៀបគ្រប់គ្រងការឆ្លងមេរោគរលាកថ្លើមប្រភេទ B របស់អ្នក។
- មានការព្យាបាលដែលអាចកាត់បន្ថយហានិភ័យនៃការចម្លងជំងឺរលាកថ្លើមប្រភេទ B ទៅកាន់ទារកអ្នក។
- បើអ្នកមិនដឹងថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B ទេ សូមស្នើសុំអ្នកថែទាំរបស់អ្នកធ្វើតេស្តឈាមរកជំងឺរលាកថ្លើមប្រភេទ B ។

## តើអ្នកអាចការពារកូនរបស់អ្នកពីការឆ្លងមេរោគយ៉ាងដូចម្ដេច?

- ធ្វើតេស្តរកជំងឺរលាកថ្លើមប្រភេទ B អំឡុងពេលមានផ្ទៃពោះរាល់លើក។
- បើអ្នកធ្វើតេស្តបានលទ្ធផលអវិជ្ជមានចំពោះជំងឺរលាកថ្លើមប្រភេទ B សូមសាកសួរអ្នកផ្ដល់សេវារបស់អ្នកអំពីការចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B ។
- បើអ្នកធ្វើតេស្តបានលទ្ធផលវិជ្ជមានសម្រាប់ជំងឺរលាកថ្លើមប្រភេទ B ទារករបស់អ្នកនឹងត្រូវការការព្យាបាល និងតាមដាន៖
  - ទារករបស់អ្នកនឹងទទួលបានការវ៉ាក់សាំងដំបូងដែលត្រូវចាក់ជាច្រើនលើក និងគ្លូប៊ុយលីនការពារជំងឺរលាកថ្លើមប្រភេទ B (HBIG) បន្ទាប់ពីកើត។
  - ទារករបស់អ្នកនឹងត្រូវបញ្ចប់ការចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B ។
  - បន្ទាប់ពីបញ្ចប់ការចាក់វ៉ាក់សាំង វេជ្ជបណ្ឌិតរបស់អ្នកនឹងបូមឈាម ដើម្បីធ្វើឲ្យប្រាកដថា កូនរបស់អ្នកត្រូវបានការពារពីជំងឺរលាកថ្លើមប្រភេទ B ។
- វាមានសុវត្ថិភាពក្នុងការបំបៅកូនដោយទឹកដោះម្ដាយ ទោះបីអ្នកមានជំងឺរលាកថ្លើមប្រភេទ B ក៏ដោយ។



Minnesota Department of Health
Perinatal Hepatitis B Prevention Program
PO Box 64975, St. Paul, MN 55164-0975
651-201-5414, 1-877-676-5414
[www.health.state.mn.us/hepatitis](http://www.health.state.mn.us/hepatitis)

Hepatitis B Information for Pregnant Women – Khmer
(4/18/19)

*ដើម្បីទទួលព័ត៌មាននេះក្នុងទម្រង់ផ្សេងៗ សូមទូរសព្ទទៅលេខ៖ 651-201-5414 ។*